01740163

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.)

## គម្រោងបញ្ចប់ផែនការ

## កំណែលើកទី ២៥

## ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០

**សេចក្តីសង្ខេប** .......... 2
I. **សេចក្តីផ្តើម** .......... 3
II. **វិធានការដែលអាចជួយបញ្ចប់កិច្ចដំណើរការនីតិវិធីបានឆាប់រហ័ស** .......... 10
III. **ផែនការបញ្ចប់ការស៊ើបអង្កេត** .......... 12
ក. ការិយាល័យសហចៅក្រមស៊ើបអង្កេត .......... 12
ខ. អង្គបុរេជំនុំជម្រះ .......... 13
IV. **ផែនការបញ្ចប់សវនាការ** .......... 15
ក. សំណុំរឿង០០២/០២ .......... 15
ខ. សំណុំរឿង០០៣ សំណុំរឿង០០៤/០២ និងសំណុំរឿង០០៤ .......... 15
V. **ផែនការបញ្ចប់បណ្តឹងសាទុក្ខ** .......... 17
ក. សំណុំរឿង០០២/០២ .......... 17
ខ. សំណុំរឿង០០៣ សំណុំរឿង០០៤/០២ និង សំណុំរឿង០០៤ .......... 18
VI. **សេចក្តីសន្និដ្ឋាន** .......... 19
ឧបសម្ព័ន្ធ ៖ តារាងកំណត់ពេលវេលាតាមការគ្រោងទុកសម្រាប់ការបញ្ចប់ផែនការ ដែលរួមមានព្រឹត្តិការណ៍សំខាន់ៗ។

**សំគាល់៖**

គម្រោងបញ្ចប់ផែនការ អ.វ.ត.ក. ត្រូវបានកែសម្រួលរៀងរាល់មួយត្រីមាសម្តង ក្នុងគោលបំណងរៀបចំផែនការ។ មាតិកានៃគម្រោងនេះរួមមានការប៉ាន់ប្រមាណនូវពេលវេលាសម្រាប់សំណុំរឿងដែលនៅសេសសល់នៃ អ.វ.ត.ក. គិតត្រឹមពេលនៃការកែសម្រួលនេះ។ កត្តាមួយចំនួន ក្នុងនោះរួមមានការវិវត្តនៃដំណើរការនីតិវិធី គឺអាចមានឥទ្ធិពលទៅលើការប៉ាន់ប្រមាណទុកទាំងនេះ។ ហេតុដូច្នេះ ពេលវេលាដែលគ្រោងទុកទាំងឡាយមិនឆ្លុះបញ្ចាំងតម្រូវការតាមផ្លូវច្បាប់ទៅលើព្រឹត្តិការណ៍សំខាន់ខុសៗគ្នានឹងត្រូវសម្រេចនៅពេលណានោះឡើយ។ គម្រោងបញ្ចប់ផែនការ អ.វ.ត.ក. ត្រូវបានរៀបចំនិងចេញដោយការិយាល័យរដ្ឋបាលដោយមានការចូលរួមយោបល់ពីការិយាល័យតុលាការទាំងអស់។

# សេចក្តីសង្ខេប

គម្រោងបញ្ចប់ផែនការសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អង្គជំនុំជម្រះ”) ត្រូវបាន រៀបចំឡើងជាលើកដំបូងនៅខែមីនា ឆ្នាំ២០១៤ ដោយឆ្លងកាត់ការពិគ្រោះពិភាក្សាយោបល់ពីសំណាក់ ការិយាល័យរដ្ឋបាល ជាមួយនឹងចៅក្រមនៃអង្គជំនុំជម្រះផ្សេងៗ សហចៅក្រមស៊ើបអង្កេត និងសហ ព្រះរាជអាជ្ញាទាក់ទិននឹងការទទួលខុសត្រូវរបស់ពួកគាត់។ នេះគឺជាការធ្វើបច្ចុប្បន្នភាពប្រចាំត្រីមាសទី ២៥ នៃគម្រោងបញ្ចប់ផែនការនេះដែលបញ្ចប់នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០។

នៅក្នុងកំឡុងត្រីមាសនេះ អង្គបុរេជំនុំជម្រះបានចេញសេចក្តីពិចារណារបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើភាពអាចទទួលយកបាននៃពាក្យសុំ តាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០៤/០២។ អង្គបុរេជំនុំជម្រះបានបន្តការពិចារណា របស់ខ្លួនលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង០០៣ និងសំណុំរឿង ០០៤។

# I. សេចក្ដីផ្ដើម

១ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អង្គជំនុំជម្រះវិសាមញ្ញ”) បានចាប់ផ្ដើមដំណើរការរបស់ខ្លួននៅខែកុម្ភៈ ឆ្នាំ២០០៦ និងបានដំណើរពេញលេញបន្ទាប់ពីការអនុម័តវិធានផ្ទៃក្នុងនៅក្នុងខែមិថុនា ឆ្នាំ២០០៧។ អណត្តិរបស់អង្គជំនុំជម្រះវិសាមញ្ញ គឺដើម្បីកាត់សេចក្ដី “មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃទី ១៧ ខែ មេសា ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩”[1]។

២ គម្រោងបញ្ចប់ផែនការនេះបានបរិយាយយ៉ាងលម្អិតដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងបរិបទនៃសេចក្ដីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ A/RES/68/247B ដែលក្នុងចំណោមបញ្ហាផ្សេងៗទៀត បានកំណត់អាណត្តិរបស់អង្គជំនុំជម្រះវិសាមញ្ញឲ្យរៀបចំយុទ្ធសាស្ត្របញ្ចប់ ដោយមានផែនទីបង្ហាញផ្លូវច្បាស់លាស់មួយ។ ឯកសារនេះធ្វើឡើងដោយអង្គជំនុំជម្រះវិសាមញ្ញដោយមានការពិគ្រោះយោបល់តាមរយៈការិយាល័យរដ្ឋបាល ជាមួយចៅក្រមអង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល សហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញាអំពីការទទួលខុសត្រូវរបស់ពួកគេ។ អង្គជំនុំជម្រះវិសាមញ្ញ ធ្វើបច្ចុប្បន្នភាពផែនការបញ្ចប់នេះរៀងរាល់ត្រីមាស។ ឯកសារនេះគឺជាកំណែលើកទី២៥ ហើយបានបញ្ចូលនូវការកែតម្រូវនានា ដោយផ្អែកលើវឌ្ឍនភាពនៃដំណើរការនីតិវិធីតាមផ្លូវតុលាការដែលកំពុងប្រព្រឹត្តទៅចាប់ពីថ្ងៃទី០១ ខែមេសា ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០។

៣ ឯកសារនេះផ្ដោតជាពិសេសលើវឌ្ឍនភាពថ្មីៗ នៅក្នុងសំណុំរឿងដែលនៅសេសសល់ទាំងបីដែលបច្ចុប្បន្នកំពុងស្ថិតនៅចំពោះមុខ អ.វ.ត.ក និងផ្ដល់នូវព័ត៌មានអំពីប្រភេទនៃរឿងក្ដី ព្រមទាំងស្ថានភាពនៃសំណុំរឿងទាំងនោះនិងជំហាននានាដែលត្រូវបំពេញមុនពេលកិច្ចដំណើរការនីតិវិធីតាមផ្លូវតុលាការទាក់ទិននឹងសំណុំរឿងកំពុងរង់ចាំបច្ចុប្បន្ននៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ បញ្ចប់ជាស្ថាពរតាមផ្លូវច្បាប់។

---

[1] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្ដីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៣។

01740166

សហព្រះរាជអាជ្ញាបានថ្លែងជាសាធារណៈថា នឹងពុំមានសំណុំរឿងបន្ថែមទៀតទេ បន្ទាប់ពីសំណុំរឿង ០០៣ និងសំណុំរឿង០០៤[2]។ ហេតុនេះ សំណុំរឿងដែលមាននាពេលនេះគឺជាសំណុំរឿងសរុបដែល អ.វ.ត.ក. ត្រូវចាត់ការតាមនីតិវិធី។

៤ **សំណុំរឿង០០១** ប្រឆាំងនឹង កាំង ហ្គេចអ៊ាវ (ហៅ ឌុច) គឺជាសំណុំរឿងដំបូងដែលបានជំនុំជម្រះនៅចំពោះមុខអង្គជំនុំជម្រះ អ.វ.ត.ក. ។ នៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ អង្គជំនុំជម្រះតុលាការកំពូលបានប្រកាសសាលដីការបស់ខ្លួន នៅក្នុងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងធ្វើឲ្យសំណុំរឿងនេះត្រូវបានបញ្ចប់ស្ថាពរ។ ជនជាប់ចោទត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត។

៥ អង្គជំនុំជម្រះបានបំបែកបទចោទនៅក្នុង**សំណុំរឿង ០០២** ទៅជាសវនាការចំនួនពីរ។ អង្គជំនុំជម្រះសាលាដំបូងបានចេញសាលក្រម នៅក្នុងសវនាការដំណាក់កាលទីមួយដែលអង្គជំនុំជម្រះវិសាមញ្ញកំណត់ឈ្មោះសំណុំរឿងថា សំណុំរឿង០០២/០១ នៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ ប្រឆាំងនឹង នួន ជា និង ខៀវ សំផន។ ជនជាប់ចោទចំនួនពីរនាក់ទៀតនៅក្នុងរឿងក្តី គឺ អៀង សារី បានទទួលមរណភាពនៅថ្ងៃទី១៤ ខែ មីនា ឆ្នាំ ២០១៣ និង អៀង ធីរិទ្ធ បានទទួលមរណភាពនៅ និងថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៥ ហេតុដូចនេះ កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងពួកគេត្រូវបានរំលត់។ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ខៀវ សំផន និង នួន ជា មានពិរុទ្ធភាពពីបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩៧៧ និងត្រូវបានផ្តន្ទាទោសម្នាក់ៗឲ្យជាប់ពន្ធនាគារអស់មួយជីវិត។ ដំណើរការនីតិវិធីបណ្តឹងសាទុក្ខក្នុងសំណុំរឿងនេះ ត្រូវបានបញ្ចប់នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ដោយមានការប្រកាសសាលដីកាអង្គជំនុំជម្រះតុលាការកំពូល ។ អង្គជំនុំជម្រះតម្កល់សាលក្រមសម្រេចផ្តន្ទាទោសអស់មួយជីវិតលើជនជាប់ចោទទាំងពីរ។

---

[2] សេចក្តីប្រកាសព័ត៌មានរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី៖ អំពីការដាក់ជូននូវដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរថ្មីៗ ចំនួន ២ ចេញផ្សាយថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០០៩ (www.eccc.gov.kh/sites/default/files/media/ECCC_Act_Int_Co_Prosecutor_8_Sep_2009_(Eng).pdf)។ សេចក្តីថ្លែងការណ៍សាធារណៈដោយសហព្រះរាជអាជ្ញាទាក់ទិននឹងការស៊ើបអង្កេតក្នុងសំណុំរឿង ០០៣ ចេញផ្សាយថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១២ (www.eccc.gov.kh/sites/default/files/media/ECCC%20OCP%205%20June%202012%20En.pdf) និងសេចក្តីថ្លែងការណ៍ដោយសហព្រះរាជអាជ្ញាអន្តរជាតិទាក់ទិននឹងបន្ទុកការងាររបស់ អ.វ.ត.ក ចេញផ្សាយថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៤ (http://www.eccc.gov.kh/en/articles/statement-international-co-prosecutor-regarding-eccc-caseload)។

៦ ការជំនុំជម្រះទីពីរកំពុងដំណើរការក្នុងពេលបច្ចុប្បន្ននេះ ដែលអង្គជំនុំជម្រះវិសាមញ្ញដាក់ឈ្មោះថា សំណុំរឿង ០០២/០២ បានផ្តោតលើជម្រើសតំណាងបទចោទមួយចំនួនដែលនៅសល់ប្រឆាំងនឹងជនជាប់ចោទ នួន ជា និង ខៀវ សំផន។ បទចោទទាំងនោះរួមមាន៖ អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិលើប្រធានបទ ការប្រព្រឹត្តិលើជនជាតិចាម វៀតណាម សហករណ៍ត្រាំកក់ (រួមទាំងមន្ទីរសន្តិសុខក្រាំងតាចាន់និងការប្រព្រឹត្តលើពុទ្ធសាសនិក) ការដ្ឋានទំនប់ ១មករា ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង មន្ទីរសន្តិសុខអូរកន្សែង ភ្នំក្រោល និងស-២១ ការបោសសម្អាតផ្ទៃក្នុង និងការដាក់បទបញ្ជាលើអាពាហ៍ពិពាហ៍។ សវនាការលើភស្តុតាងចាប់ផ្តើមនៅថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៥ ហើយបញ្ចប់នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០១៧។ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសង្ខេបផ្ទាល់មាត់ទៅលើសម្អាងហេតុនិងសេចក្តីសម្រេចនៃសាលក្រម នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ និងចេញសាលក្រមទាំង០៣ភាសាធ្វើការ នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩។ អង្គជំនុំជម្រះ រកឃើញថា ខៀវ សំផន និង នួន ជា មានពិរុទ្ធភាពពីបទប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ហើយបានផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត[3]។ ក្រោយពីទទួលសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា នួន ជា និង ខៀវ សំផន អង្គជំនុំជម្រះសាលាដំបូងបានបញ្ជូនសំណុំរឿងទៅអង្គជំនុំជម្រះតុលាការកំពូលនៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩។

៧ នៅថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៩ នួន ជា ទទួលមរណភាពក្នុងអាយុ៩៣ឆ្នាំ ខណៈដែលទទួលព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត។ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ចប់កិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខប្រឆាំងនឹង នួន ជា នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៩។ នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩ អង្គជំនុំជម្រះតុលាការកំពូលបានបំភ្លឺបញ្ជាក់ថា ការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹង នួន ជា ពុំត្រូវបានចាត់ទុកឥតបានការនោះទេក្រោយពីទទួលមរណភាព ហើយបានបញ្ជាក់ថា តុលាការពុំអាចបន្តកិច្ចដំណើរការនីតិវិធីនៅក្នុងរឿងក្តីប្រឆាំងនឹង នួន ជា បន្តទៀតនោះទេ។

៨ នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៧ អង្គជំនុំជម្រះសាលាដំបូង បានចេញសេចក្តីសម្រេចបញ្ចប់កិច្ចនីតិវិធីពាក់ព័ន្ធនឹងអង្គហេតុដែលមានចែងនៅក្នុងដីកាដំណោះស្រាយក្នុងសំណុំរឿង០០២ ដែលមិនមាន

---

[3] សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អសជ (https://www.eccc.gov.kh/en/document/court/case-00202-judgement)។

បញ្ចូលនៅក្នុងសំណុំរឿង០០២/០១ ឬ០០២/០២។ ហេតុដូច្នេះ ដំណើរការនីតិវិធីតុលាការក្នុងសំណុំរឿង០០២ នឹងត្រូវបញ្ចប់នៅពេលសាលក្រមសំណុំរឿង០០២/០២ ចូលជាស្ថាពរ។

៩ កិច្ចស៊ើបសួរនៅក្នុង**សំណុំរឿង ០០៣ និង ០០៤** បានផ្តួចផ្តើមឡើងក្រោយពេលសហព្រះរាជអាជ្ញាអន្តរជាតិចេញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនៅក្នុងឆ្នាំ២០០៩ ហើយបន្ទាប់មកចេញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម។ បន្ទាប់មក សំណុំរឿង ០០៤ ត្រូវបានបំបែកចេញជាសំណុំរឿងចំនួនបី ពោលគឺ សំណុំរឿង ០០៤/០១ ពាក់ព័ន្ធនឹង អ៊ឹម ចែម សំណុំរឿង ០០៤/០២ ពាក់ព័ន្ធនឹង អោ អាន និង សំណុំរឿងដែលនៅសេសសល់ គឺ សំណុំរឿង ០០៤ ប្រឆាំងនឹង យឹម ទិត្យ។

១០ នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយ ដោយមានសម្អាងហេតុលើកលែងចោទប្រកាន់**សំណុំរឿង ០០៤/០១** ប្រឆាំងនឹង អ៊ឹម ចែម។ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយនៅមុខអង្គបុរេជំនុំជម្រះ។ នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ អង្គបុរេជំនុំជម្រះ បានសម្រេចលើបណ្តឹងឧទ្ធរណ៍លើយុត្តាធិការបុគ្គល ក្នុងនោះរួមមាន នីតិវិធីតុលាការក្នុងសំណុំរឿងនេះផងដែរ។ សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតដែលថា អង្គជំនុំជម្រះវិសាមញ្ញមិនមានយុត្តាធិការលើ អ៊ឹម ចែម ចាត់ទុកជាបានការដែលជាការបញ្ចប់ដំណើរការនីតិវិធីតុលាការក្នុងសំណុំរឿងនេះ។

១១ ដំណើរការនីតិវិធីសំណុំរឿង០០៣ សំណុំរឿង០០៤/០២ និងសំណុំរឿង០០៤ មានវឌ្ឍនភាព ដូចខាងក្រោម៖

ក- នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយចំនួនពីរផ្សេងគ្នា ក្នុងសំណុំរឿង០០៣ ប្រឆាំង មាស មុត ជាភាសាធ្វើការរបស់ចៅក្រមនីមួយៗ (ខ្មែរ និងអង់គ្លេស) ដែលការបកប្រែនឹងដាក់តាមក្រោយ។ ចៅក្រមស៊ើបអង្កេតអន្តរជាតិចោទប្រកាន់ មាស មុត ពីអំពីអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និង បទល្មើសក្រោមច្បាប់ជាតិ។ សហចៅក្រមស៊ើបអង្កេតជាតិបានទម្លាក់ការចោទប្រកាន់ដោយមូលហេតុពុំមានយុត្តាធិការបុគ្គល។ ដីកាសំណោះស្រាយទាំងពីរមានអមដោយសេចក្តីសម្រេចលើពាក្យសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ សំណៅបកប្រែដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតជាតិជាភាសាអង់គ្លេសនៅក្នុងសំណុំរឿងនេះ ត្រូវបានជូនដំណឹងនៅថ្ងៃទី០១ ខែកុម្ភៈ ចំណែកសំណៅបកប្រែដីកាដំណោះស្រាយជាភាសាខ្មែរត្រូវបានជូនដំណឹងនៅថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៩។ បណ្តឹងឧទ្ធរណ៍ចំនួនបីត្រូវបានដាក់

ប្រឆាំងនឹងដីកាដំណោះស្រាយ។ មេធាវីការពារក្តី និងសហព្រះរាជអាជ្ញាជាតិបានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)។ ចំណែកឯសហព្រះរាជអាជ្ញាអន្តរជាតិប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេតជាតិ។ ចម្លើយតប និងការឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍ទាំងអស់ត្រូវបានដាក់ដោយភាគី ជាភាសាអង់គ្លេស និងភាសាខ្មែរ នៅចុងត្រីមាសទី៣ ឆ្នាំ២០១៩។ ជាងនេះទៀត នៅថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៩ ដើមបណ្តឹងរដ្ឋប្បវេណីបានដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សចៅក្រមស៊ើបអង្កេតអន្តរជាតិលើភាពទទួលយកបាននៃដើមបណ្តឹងរដ្ឋប្បវេណី។ នៅថ្ងៃទី២៧ ដល់ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩ អង្គបុរេជំនុំជម្រះបានបើកសវនាការចំនួន០៣ថ្ងៃ លើបណ្តឹងឧទ្ធរណ៍ទាំងឡាយប្រឆាំងនឹងដីកាដំណោះស្រាយ។ នៅថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២០ សហមេធាវីការពារក្តី មាស មុត បានដាក់ឯកសារក្នុងលក្ខខណ្ឌសម្ងាត់បន្ថែមលើបណ្តឹងឧទ្ធរណ៍របស់ខ្លួនប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ចម្លើយតបរបស់សព្រះរាជអាជ្ញា និងការឆ្លើយតបរប់សហមេធាវីត្រូវបានសង្ខេបដោយពេញលេញនៅត្រឹមថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២។ អង្គបុរេជំនុំជម្រះបានព្យាករណ៍ថានឹងអាចចេញសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ នៅត្រឹមត្រីមាសទី៣ ក្នុងឆ្នាំ២០២០។

ខ- នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយចំនួនពីរផ្សេងគ្នាក្នុងសំណុំរឿង00៤/0២ ប្រឆាំងនឹង អោ អាន ជាភាសាដែលចៅក្រមធ្វើការ (ភាសាខ្មែរ និងភាសាអង់គ្លេស) ហើយការបកប្រែនឹងដាក់ជូនតាមក្រោយ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សម្រេចចោទប្រកាន់ អោ អាន ពីបទប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងបទល្មើស តាមច្បាប់ជាតិមួយចំនួនទៀត។សហចៅក្រមជាតិបានទម្លាក់ការចោទប្រកាន់ ដោយហេតុពុំមានយុត្តាធិការបុគ្គល។ ដីកាដំណោះស្រាយមានអមដោយសេចក្តីសម្រេចលើសំណើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ សំណៅបកប្រែជាភាសាខ្មែរនិងអង់គ្លេសនៃដីកាដំណោះស្រាយត្រូវបានជូនដំណឹង នៅថ្ងៃទី៣០ ខែតុលា និងថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ ២០១៨។ បណ្តឹងឧទ្ធរណ៍ចំនួន ០៣ ត្រូវបានដាក់ប្រឆាំងនឹងដីកាដំណោះស្រាយ៖ ពោលគឺមេធាវីការពារក្តី និងសហព្រះរាជអាជ្ញា ជាតិប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ(ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចំណែកឯសហព្រះរាជអាជ្ញាអន្តរជាតិ បានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេតជាតិ។ នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៨ ដើមបណ្តឹងរដ្ឋប្បវេណីបានដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹង

ដីកាសម្រេចរបស់សចៅក្រមស៊ើបអង្កេតលើភាពទទួលយកបាននៃដើមបណ្តឹងរដ្ឋប្បវេណី។ អង្គបុរេជំនុំជម្រះ បានធ្វើសវនាការចំនួន០៣ថ្ងៃលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងខែមិថុនា ឆ្នាំ២០១៩។ នៅថ្ងៃទី១៩ ខែធ្នូ អង្គបុរេជំនុំជម្រះបានដាក់សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកា ដំណោះស្រាយ ដោយបានប្រកាសជាឯកច្ឆ័ន្ទ "ថា ការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នារបស់សហចៅក្រមស៊ើបអង្កេតធ្វើឡើងដោយខុសច្បាប់"។ ដោយសារអង្គជំនុំជម្រះមិន "អាចរកបានសម្លេងភាគច្រើនលើសលប់នៃសម្លេងគាំទ្រចំនួនបួន តាមការកំណត់ ដើម្បីឈានទៅធ្វើសេចក្តីសម្រេចផ្អែក លើសំអាងហេតុរួមលើអង្គសេចក្តីបាន" ចៅក្រមបានដាក់មតិយោបល់របស់ខ្លួនភ្ជាប់មកជាមួយសេចក្តីពិចារណាជាឯកច្ឆ័ន្ទនេះ[4]។ នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ អង្គបុរេជំនុំជម្រះបានចេញសេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើភាពអាចទទួលយកបាននៃដើមបណ្តឹងរដ្ឋប្បវេណី ដោយសម្រេចជាឯកច្ឆ័ន្ទថាបណ្តឹងឧទ្ធរណ៍អាចទទួលយកបាន។ អង្គបុរេជំនុំជម្រះប្រកាសថាខ្លួន "អាចរកបានសម្លេងភាគច្រើនលើសលប់នៃសម្លេងគាំទ្រចំនួនបួនតាមការកំណត់ដើម្បីឈានទៅធ្វើសេចក្តីសម្រេចផ្អែកលើសំអាងហេតុរួមលើអង្គសេចក្តីបាន" ហើយចៅក្រម បានភ្ជាប់ទស្សនៈរបស់ខ្លួនទៅនឹងសេចក្តីពិចារណា[5]។

គ- នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយពីរផ្សេងគ្នាក្នុងសំណុំរឿង ០០៤ ប្រឆាំងនឹង យឹម ទិត្យ ជាភាសារបស់ចៅក្រមនីមួយៗ (ភាសាខ្មែរ និងអង់គ្លេស) និងការបកប្រែដាក់ជូនពេលក្រោយ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិសម្រេចចោទប្រកាន់ យឹម ទិត្យ ពីបទប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងបទ

[4] នៅចំពោះមុខអង្គបុរេជំនុំជម្រះ ភាគីបានសាកសួរអំពីផលវិបាកផ្អែកនីតិវិធីនៃសេចក្តីពិចារណានេះ។ ប្រធាន និងចៅក្រមអង្គបុរេជំនុំជម្រះពីររូបបានចេញលិខិតឆ្លើយឆ្លងដោយឡែក ដោយបានលើកឡើងថា អង្គជំនុំជម្រះពុំចាំបាច់ចាត់វិធានការអ្វីបន្ថែមដើម្បីអនុវត្តសេចក្តីពិចារណារបស់ចៅក្រមនោះឡើយ។ លិខិតឆ្លើយឆ្លងទាំងពីរអាចរកបាននៅលើគេហទំព័រ https://eccc.gov.kh/en/document/court/presidents-memorandum-dated-16-march-2020 និង https://eccc.gov.kh/en/document/court/international-judges-memorandum-concerning-transfer-case-file-0042.។

[5] ចៅក្រមជាតិសម្រេចថាអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០៤/០២ត្រូវតែបដិសេធ។ ចៅក្រមអន្តរជាតិសម្រេចថាអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន១២នាក់បន្ថែមគួរតែត្រូវបានទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០៤/០២។ ប៉ុន្តែទោះជាយ៉ាងនេះក្តី ដោយហេតុថាពុំអាចរកសំឡេងគាំទ្រភាគច្រើនតាមការកំណត់ ចៅក្រមអន្តរជាតិសម្រេចថាដីកាលើភាពទទួលយកបាននៃដើមបណ្តឹងរដ្ឋប្បវេណីដែលរងបណ្តឹងឧទ្ធរណ៍ត្រូវតែចាត់ទុកជាបានការ។

ល្មើសតាមច្បាប់កម្ពុជា។ សហចៅក្រមស៊ើបអង្កេតជាតិសម្រេចលើកលែងចោទប្រកាន់ ដោយមូលហេតុពុំមានយុត្តាធិការបុគ្គល។ ដីកាដំណោះស្រាយមានអមដោយសេចក្តីសម្រេចលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ សំណៅបកប្រែជាភាសាខ្មែរនៃដីកាដំណោះស្រាយត្រូវបានជូនដំណឹងនៅថ្ងៃទី១៤ ខែសីហា ចំណែកឯភាសាអង់គ្លេស នៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៩។ បណ្តឹងឧទ្ធរណ៍ចំនួន ០៥ ត្រូវបានដាក់ប្រឆាំងនឹងដីកាដំណោះស្រាយ៖ មេធាវីការពារក្តី និងសហព្រះរាជអាជ្ញាជាតិបានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) សហព្រះរាជអាជ្ញាអន្តរជាតិ និងដើមបណ្តឹងរដ្ឋប្បវេណីបានបានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាលើកលែងការចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេតជាតិ ហើយមេធាវីការពារក្តីក៏បានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងការចេញដីកាដំណោះស្រាយដោយឡែកពីគ្នាផងដែរ។ លើសពីនេះទៀត នៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៩ ដើមបណ្តឹងរដ្ឋប្បវេណីបានដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើភាពទទួលយកបាននៃដើមបណ្តឹងរដ្ឋប្បវេណី។ អង្គបុរេជំនុំជម្រះបានព្យាករថានឹងចេញសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយនៅត្រីមត្រីមាសទី១ ក្នុងឆ្នាំ២០២១។

១២ តាមរយៈការវិវត្តក្នុងត្រីមាសចុងក្រោយនេះ គម្រោងបញ្ចប់ផែនការរបស់អង្គជំនុំ ជម្រះវិសាមញ្ញកំណត់ព្រឹត្តិការណ៍សំខាន់ចំនួនបីសម្រាប់សំណុំរឿងដែលអង្គជំនុំជម្រះបានទទួល។ ព្រឹត្តិការណ៍សំខាន់ដែលនៅសេសសល់ចំនួនពីរនៅក្នុងសំណុំរឿង០០២ និងការព្យាករណ៍ដែលពាក់ព័ន្ធគឺ៖

(i) ការចេញសាលដីកាជាភាសាផ្លូវការទាំងបីភាសា (ត្រីមាសទី៤ ឆ្នាំ២០២២)។

១៣ នៅក្នុងសំណុំរឿង០០៣ និងសំណុំរឿង០០៤ ព្រឹត្តិការណ៍ដ៏សំខាន់សរុបចំនួន០២ ត្រូវបានកំណត់សម្រាប់ដំណាក់កាលបណ្តឹងឧទ្ធរណ៍លើកិច្ចស៊ើបសួរ។ ក្នុងករណីមានការចោទប្រកាន់ នឹងមានព្រឹត្តិការណ៍សំខាន់បន្ថែមទៀតសម្រាប់ដំណាក់កាលជំនុំជម្រះនិងបណ្តឹងសាទុក្ខ[6]។ ព្រឹត្តិការណ៍សំខាន់សម្រាប់ដំណាក់កាលបណ្តឹងឧទ្ធរណ៍លើកិច្ចស៊ើបសួរដែលបន្តនៅសេសសល់ គឺ៖

[6] ដោយសារស្ថានភាពនៃកិច្ចដំណើរការនីតិវិធីបច្ចុប្បន្ន នៅពេលនេះយើងមិនអាចព្យាករចំណុចពេលវេលាជាក់លាក់ទាក់ទិននឹងគ្រោងការជំនុំជម្រះក្តីបានឡើយ។

(ii) សេចក្តីសម្រេចដោយអង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង០០៣ ថាតើត្រូវបញ្ជូនរឿងទៅជំនុំជម្រះ ឬបញ្ចប់កិច្ចនីតិវិធីក្នុងសំណុំរឿងនោះ (ត្រីមាសទី៣ ឆ្នាំ២០២០) និង

(iii) សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះទៅលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង០០៤ ថាតើបញ្ជូនរឿងទៅជម្រះ ឬក៏បញ្ចប់កិច្ចនីតិវិធី (ត្រីមាសទី១ ឆ្នាំ២០២១)។

## II. វិធានការដែលអាចជួយបញ្ចប់កិច្ចដំណើរការនីតិវិធីបានឆាប់រហ័ស

១៤ ដំណើរការប្រកបដោយប្រសិទ្ធិភាពរបស់អង្គជំនុំជម្រះវិសាមញ្ញកន្លងទៅត្រូវបានរំខាន ដោយភាពមិននឹងនថ្នែកហិរញ្ញវត្ថុដែលចេះតែបន្តកើតមាន ដែលបណ្តាលឲ្យបុគ្គលិកជាតិធ្វើកូដកម្មមិនធ្វើការចំនួនពីរលើកក្នុងអំឡុងឆ្នាំ២០១៣ ព្រមទាំងបុគ្គលិកចេញចូលពីមុខតំណែងដោយមិនសមហេតុផល។ ការអនុម័តរបស់ មហាសន្និបាតទៅលើឧបត្ថម្ភធនសម្រាប់ឆ្នាំសារពើពន្ធ២០១៤-២០២០ សម្រាប់ភាគីអន្តរជាតិនៃ អ.វ.ត.ក គឺជាវិធានការដ៏សំខាន់ដែលបានធ្វើឲ្យមានស្ថិរភាពដល់ស្ថានភាពថវិកានិងធ្វើឲ្យមានការផ្តោតមូលទៅ លើការធ្វើឲ្យវិវត្តទៅមុខនៃអាណត្តិតុលាការ។ ចំពោះភាគីជាតិវិញ ការលំបាកផ្នែកលំហូរសាច់ប្រាក់ បាននាំឲ្យមានការពន្យារពេលបើកប្រាក់បៀវត្សសម្រាប់បុគ្គលិកជាតិនៅក្នុងកំឡុងពាក់កណ្តាល ឆ្នាំ២០១៥ ដែលប៉ះពាល់ដល់ការផ្តោតអារម្មណ៍ និងទឹកចិត្តបំពេញការងារ។

១៥ ក្រោយពីមានការសម្តែងនូវការគាំទ្រពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា មហាសន្និបាតអង្គការសហប្រជាជាតិក្នុងលក្ខណៈជាវិធានការពិសេស បានអនុញ្ញាតឲ្យអគ្គលេខាធិការសម្រេច កំណត់ទឹកប្រាក់ចំនួនមិនលើសពី ៧ លានដុល្លារ នៅក្នុងខែធ្នូ ឆ្នាំ២០១៩ ដើម្បីបន្ថែមបង្គ្រប់ធនធានថវិកាស្ម័គ្រចិត្តរបស់ភាគីអន្តរជាតិនៃ អ.វ.ត.ក សម្រាប់រយៈពេលគិតចាប់ពីថ្ងៃទី០១ ខែមករា ដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០។ គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ ទឹកប្រាក់ប្រហែល ៥០% ឬ ៣,៥ លានដុល្លារ ត្រូវបានយកមកប្រើប្រាស់ ហើយអាចនឹងមានការដកទឹកប្រាក់ទាំងអស់សម្រាប់យកមកប្រើប្រាស់ នៅក្នុងឆ្នាំនេះ។ សកម្មភាពទាន់ពេលវេលានេះបានជួយសម្រួលយ៉ាងច្រើនដល់ប្រតិបត្តិការនៅ អ.វ.ត.ក មិនឲ្យរអាក់រអួលក្នុងកំឡុង៦ខែដំបូងនៃឆ្នាំ២០២០ ដោយបើកឱកាសឲ្យមានការរៃអង្គាសថវិកាស្ម័គ្រចិត្តបន្តទៀត។ ជាងនេះទៀត ការសម្រេចរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការផ្តល់វិភាគទានដោយផ្ទាល់

ចំនួន ៣,៨ លានដុល្លារ ដើម្បីចំណាយទៅលើប្រាក់បៀវត្សបុគ្គលិកជាតិ ០៦ ខែដំបូង ក៏ដូចជាចំណាយប្រតិបត្តិការសម្រាប់ឆ្នាំ២០២០ គឺជាវិធានការដ៏សំខាន់ដែលជួយដល់ប្រតិបត្តិការបច្ចុប្បន្នរបស់ភាគីជាតិនៃ អ.វ.ត.ក។ ដោយរួមបញ្ចូលគ្នាបែបនេះ វិធានការទាំងនេះធានាថា ទំហំការងារបច្ចុប្បន្នរបស់ អ.វ.ត.ក បានបន្តទទួលបាននូវការយកចិត្តទុកដាក់ជានិច្ច។ វិភាគទានស្ម័គ្រចិត្តដែលបានសន្យាផ្តល់ជូន និងទទួលបាននៅត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ មានចំនួន ៤ លានដុល្លារ សម្រាប់ភាគីអន្តរជាតិ។ អង្គជំនុំជម្រះវិសាមញ្ញបន្តការងារអែអង្គាសថវិកាបន្ថែម ពីសហគមន៍ម្ចាស់ជំនួយអន្តរជាតិឲ្យគ្រប់ថវិកាដែលបានអនុម័តចំនួន ១៣,៥ លានដុល្លារសម្រាប់ភាគីអន្តរជាតិ និង ៥ លានដុល្លារសម្រាប់ភាគីជាតិ។

១៦ នៅខែមករា ឆ្នាំ២០១៥ កិច្ចប្រជុំពេញអង្គនៃ អ.វ.ត.ក បានអនុម័តវិសោធនកម្មទៅលើវិធានផ្ទៃក្នុង ដែលអនុញ្ញាតឲ្យមានការកាត់បន្ថយទៅលើវិសាលភាពកិច្ចស៊ើបសួរល្អិតណាវិសាលភាពស៊ើបអង្កេតដែលបានកាត់បន្ថយជាតំណាងឲ្យបទចោទ និងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនសង្ស័យតាមការចោទប្រកាន់[7]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរពាក់ព័ន្ធនឹង មាស មុត ក្នុងសំណុំរឿង០០៣, អោ អាន ក្នុងសំណុំរឿង០០៤/០២ និង យឹម ទិត្យ ក្នុងសំណុំរឿង ០០៤ អនុលោមតាមបទបញ្ញត្តិនេះ។ ស្រដៀងគ្នានេះដែរ អង្គជំនុំជម្រះសាលាដំបូងមានសិទ្ធិអំណាចកាត់បន្ថយវិសាលភាពនៃការជំនុំជម្រះក្តីមួយដោយមិនរួមបញ្ចូលអង្គហេតុជាក់លាក់មួយចំនួនដែលមានចែងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដរាបណាអង្គហេតុដែលនៅសល់ដែលត្រូវជម្រះ គឺជាតំណាងវិសាលភាពនៃដីកាបញ្ជូនរឿងទៅជម្រះ[8]។ ឈរលើមូលដ្ឋាននេះ អង្គជំនុំជម្រះសាលាដំបូងបានបញ្ចប់កិច្ចនីតិវិធីពាក់ព័ន្ធនឹងអង្គហេតុដែលមានចែងក្នុងសំណុំរឿង០០២ ដែលមិនមានបញ្ចូលនៅក្នុងសំណុំរឿង ០០២/០១ ឬ០០២/០២។

១៧ ការិយាល័យរដ្ឋបាលបានរក្សាសេវាកម្មរបស់បុគ្គលិកឯកទេសភាសាបន្ថែមទៀត ដើម្បីគាំទ្រដល់ការិយាល័យតុលាការ ដើម្បីធានាសេវាបកប្រែ និងប្រតិចារឹកបានទាន់ពេលវេលា។

១៨ នៅក្នុងខែមីនា ឆ្នាំ២០២០ ការិយាល័យរដ្ឋបាលបានចាត់វិធានការទប់ស្កាត់ការចម្លងជំងឺកូវីដ-១៩ នៅ អ.វ.ត.ក។ គិតត្រឹមថ្ងៃទី២៥ ខែមីនា ការរៀបចំបែបផែនបំពេញការងារបណ្តោះអាសន្ន រួមមាន

---

[7] វិធាន៦៦ស្ទួន។

[8] វិធាន៨៩*ស្ទួន៣*។

ការបំពេញការងារពីចម្ងាយត្រូវបានដាក់ចេញអនុវត្តសម្រាប់គ្រប់បុគ្គលទាំងអស់ ដែលអាចមានសិទ្ធិចូលមើលប្រភពឯកសារពីចម្ងាយ ក្នុងគោលបំណងជួយសម្រួលដល់និរន្តរភាពដំណើរការរដ្ឋបាល និង តុលាការ[9]។

## III. ផែនការបញ្ចប់ការស៊ើបអង្កេត

១៩ ដំណាក់កាលស៊ើបអង្កេតរួមមានយុត្តាធិការរបស់ (ក) ការិយាល័យសហចៅក្រមស៊ើបអង្កេត និង (ខ) អង្គបុរេជំនុំជម្រះ នៅដំណាក់កាលបណ្តឹងឧទ្ធរណ៍។

២០ កិច្ចស៊ើបសួរនៅក្នុងសំណុំរឿង ០០៣ និង ០០៤ បានផ្តួចផ្តើមឡើងក្រោយពេលសហព្រះរាជអាជ្ញាអន្តរជាតិចេញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ នៅក្នុងឆ្នាំ២០០៨ ហើយនឹងក្រោយពេលចេញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម។សំណុំរឿង ០០៤ ត្រូវបានបំបែកចេញជាសំណុំរឿងចំនួនបីដោយឡែកពីគ្នា ពោលគឺ សំណុំរឿង ០០៤/០១ ពាក់ព័ន្ធនឹង អ៊ឹម ចែម សំណុំរឿង ០០៤/០២ ពាក់ព័ន្ធនឹង អោ អាន និងសំណុំរឿង០០៤ ដែលនៅសល់ គឺសំណុំរឿងប្រឆាំង យឹម ទិត្យ។

## ក. *ការិយាល័យសហចៅក្រមស៊ើបអង្កេត*

២១ នៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០ Michael Bohlander ត្រូវបានតែងតាំងសាជាថ្មីជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិ។ អាណត្តិតាមកំណត់ច្បាប់របស់សហចៅក្រមស៊ើបអង្កេតនឹងបញ្ចប់នៅថ្ងៃតែមួយជាមួយអាណត្តិរបស់អង្គបុរេជំនុំជម្រះ។

២២ នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០ មេធាវីការពារក្តីបានដាក់សំណើសុំសហចៅក្រមស៊ើបអង្កេតបិទបោះត្រា និងធ្វើបណ្ណសារសំណុំរឿង០០៤/០២[10]។ នៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២០ សហចៅក្រមស៊ើបអង្កេតជូនដំណឹងដល់ភាគីថា ខ្លួនផ្អាកសេចក្តីសម្រេចសិន ដោយរង់ចាំសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិ[11]។

---

[9] ការរៀបចំនេះចាប់ផ្តើមអនុវត្តសម្រាប់ភាគីអន្តរជាតិចាប់ពីថ្ងៃទី២៣ ខែមីនា និងសម្រាប់ភាគីជាតិចាប់ពីថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០។

[10] ឯកសារនេះត្រូវបានដាក់ដំបូងក្នុងលក្ខខណ្ឌសម្ងាត់និងបន្ទាប់មកជូនដំណឹងជាសាធារណៈនៅថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២០។

[11] សូមមើលខាងក្រោម កថាខណ្ឌទី៣០។

## ខ. *អង្គបុរេជំនុំជម្រះ*

២៣ ក្នុងពេលចាប់ផ្ដើមត្រីមាសទី២ ឆ្នាំ២០២០ អង្គបុរេជំនុំជម្រះបានទទួលបណ្ដឹងចំនួន១៣ ពោលគឺសំណើបន្ទាន់បង្ខំចំនួន ១ និង បណ្ដឹងឧទ្ធរណ៍ចំនួន ៤ ក្នុងសំណុំរឿង០០៣ (បណ្ដឹងឧទ្ធរណ៍ចំនួន១ ពាក់ព័ន្ធនឹងការទទួលស្គាល់ដើមបណ្ដឹងរដ្ឋប្បវេណី និងបណ្ដឹងឧទ្ធរណ៍ចំនួន ៣ ទៀត ពាក់ព័ន្ធនឹងដីកាដំណោះស្រាយ) សំណើបន្ទាន់បង្ខំចំនួន ១ និងបណ្ដឹងឧទ្ធរណ៍ចំនួន ១ ក្នុងសំណុំរឿង០០៤/០២ (ពាក់ព័ន្ធការទទួលស្គាល់ដើមបណ្ដឹងរដ្ឋប្បវេណី) និងបណ្ដឹងឧទ្ធរណ៍ចំនួន ៦ (បណ្ដឹងឧទ្ធរណ៍ចំនួន ១ ពាក់ព័ន្ធនឹងការទទួលស្គាល់ដើមបណ្ដឹងរដ្ឋប្បវេណី និងបណ្ដឹងឧទ្ធរណ៍ចំនួន ៥ ទៀត ពាក់ព័ន្ធនឹងដីកាដំណោះស្រាយ) ក្នុងសំណុំរឿង០០៤។ នៅក្នុងរយៈពេលធ្វើរបាយការណ៍ អង្គបុរេជំនុំជម្រះបានទទួលបណ្ដឹងបន្ថែមចំនួន ៣ និងបានចេញសេចក្ដីសម្រេចបន្ទាន់បង្ខំចំនួន ២ ក្នុងសំណុំរឿង០០៣ ចេញសេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ពាក់ព័ន្ធនឹងការទទួលស្គាល់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០៤/០២ និងចេញដីកាសម្រេចចាត់ថ្នាក់ឯកសារឡើងវិញ ក្នុងសំណុំរឿង០០៤/០២។ នៅចុងរយៈពេលធ្វើរបាយការណ៍ បណ្ដឹងចំនួន ១២ នៅតែរង់ចាំការសម្រេចនៅមុខអង្គបុរេជំនុំជម្រះក្នុងសំណុំរឿង០០៣ និង ០០៤ ព្រមទាំងសំណើបន្ទាន់បង្ខំចំនួនមួយក្នុងសំណុំរឿង០០៤/០២[12]។

២៤ អង្គបុរេជំនុំជម្រះមានបំណងចេញសេចក្ដីសម្រេចលើដីកាដំណោះស្រាយក្នុងសំណុំរឿង០០៣ និងសំណុំរឿង ០០៤ ក្នុងពេលវេលាសមស្រប អាស្រ័យលើលក្ខខណ្ឌចាប់ពីពេលទទួលដីកាសន្និដ្ឋាននានា និងការដាក់បណ្ដឹងឧទ្ធរណ៍មួយចំនួនដែលអាចប៉ាន់ស្មានសាជាថ្មីថាត្រូវការចំនួន ៤ ត្រីមាស ក្រោយពីទទួលបានសារណាពេញលេញលើបណ្ដឹងឧទ្ធរណ៍[13]។ ដើម្បីចេញសម្រេចលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើការទទួលស្គាល់ដើមបណ្ដឹងរដ្ឋប្បវេណី អង្គជំនុំជម្រះអាចត្រូវការពេលវេលាប្រមាណពីរត្រីមាស ក្រោយពេលចេញសេចក្ដីសម្រេចទៅលើបណ្ដឹងណាមួយប្រឆាំងនឹងដីកាដំណោះស្រាយដើម្បីសម្រេចលើបណ្ដឹងទាំងអស់នោះ ផ្អែកតាមបទពិសោធន៍នៅក្នុងសំណុំរឿង ០០៤/០២។

២៥ ដើម្បីទទួលបានសេចក្ដីសន្និដ្ឋានពេញលេញអំពីបណ្ដឹងឧទ្ធរណ៍ សេចក្ដីសន្និដ្ឋានលើបណ្ដឹងឧទ្ធរណ៍ ចម្លើយតបទៅនឹងសេចក្ដីសន្និដ្ឋានទាំងនោះ និងការឆ្លើយតបទៅនឹងចម្លើយតបទាំងនោះ ត្រូវដាក់ជា

---

12 សំណើបន្ទាន់បង្ខំមាននៅក្នុង https://www.eccc.gov.kh/en/document/court/civil-party-lawyers-request-necessary-measures-be-taken-pre-trial-chamber-safeguard។

13 ការព្យាករណ៍នេះត្រូវបានប៉ាន់ស្មានឡើងវិញពី ២ ទៅ ៤ ត្រីមាសនៅក្នុងកំណែលើកទី២៤ នៃគម្រោងបញ្ចប់ផែនការនេះ។

ភាសាខ្មែរ និងជាភាសាអង់គ្លេស ឬបារាំង។ ការចេញដីកាដំណោះស្រាយចំនួនពីរផ្សេងគ្នា និងផ្ទុយគ្នាក្នុងសំណុំរឿង០០៣, ០០៤ និង ០០៤/០២ ដែលពុំធ្លាប់មានពីមុនមក និងការចេញដីកាដំណោះស្រាយជាភាសារបស់សហចៅក្រមរៀងៗខ្លួន ត្រូវការពេលវេលាបន្ថែមសម្រាប់ធ្វើសារណាលើបណ្ដឹងឧទ្ធរណ៍ឲ្យបានពេញលេញ។

២៦ គិតត្រឹមត្រីមាសទី២ ចៅក្រមទាំងអស់នៃអង្គបុរេជំនុំជម្រះ ដែលកំពុងបំពេញការងារ រួមទាំងចៅក្រមបម្រុងអន្តរជាតិ កំពុងចាត់ការលើដំណើរការបណ្តឹងជិតចិត្តអនុលោមវិធាន ៣៤(៦) នៅក្នុងសំណុំរឿង ០០២/០២[14]។ ជាផលវិបាក និងអាស្រ័យលើកាលៈទេសៈនៃបុគ្គលិករបស់អង្គបុរេជំនុំជម្រះ បណ្តឹងដែលពុំបានមើលឃើញពីមុនពាក់ព័ន្ធនឹងសំណុំរឿងបច្ចុប្បន្ន និងការបកប្រែបានលឿនលើសេចក្តីសន្និដ្ឋានរបស់ភាគី និងសេចក្តីសម្រេចតុលាការជាបីភាសាធ្វើការទាំងអស់របស់អង្គជំនុំជម្រះវិសាមញ្ញ ការប៉ាន់ស្មាននាពេលបច្ចុប្បន្នមានដូចខាងក្រោម៖

ក. ក្នុង*សំណុំរឿង ០០៣* បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយទាំងពីរត្រូវបានផ្តល់សារណាពេញលេញនៅត្រឹមថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៩។ ការប៉ាន់ស្មានបច្ចុប្បន្នសម្រាប់ការបញ្ចប់សំណុំរឿង ០០៣ គឺនឹងមានសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយចេញនៅត្រឹមត្រីមាសទី៣ ឆ្នាំ២០២០។ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមអន្តរជាតិលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អាចនឹងរំពឹងទុកត្រឹមត្រីមាសទី១ ឆ្នាំ២០២១។

ខ ក្នុង*សំណុំរឿង ០០៤* បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយបានដាក់សារណាពេញលេញនៅត្រឹមថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០។ ការគ្រោងទុកបច្ចុប្បន្នសម្រាប់ការបញ្ចប់សំណុំរឿង០០៤ គឺនឹងមានសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ អាស្រ័យលើភាពស្មុគស្មាញ និងទំហំនៃបណ្តឹងឧទ្ធរណ៍ ត្រឹមត្រីមាសទី១ ឆ្នាំ២០២១។ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អាចរំពឹងថាចេញនៅត្រឹមត្រីមាសទី៣ ឆ្នាំ២០២១។

[14] មើលខាងក្រោម កថាខណ្ឌ ៣៤។

## IV. ផែនការបញ្ចប់សវនាការ

### ក. *សំណុំរឿង០០២/០២*

២៧ កិច្ចដំណើរការនីតិវិធីលើភស្តុតាងបានចាប់ផ្តើមនៅថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៥ និងបានបញ្ចប់នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០១៧ ក្រោយពីពេលសវនាការអស់ចំនួន២៧៤ថ្ងៃ។ អង្គជំនុំជម្រះបានស្តាប់សក្ខីកម្មសាក្សីសរុបចំនួន១១៤ ដើមបណ្តឹងរដ្ឋប្បវេណីសរុបចំនួន ៦៣នាក់ និង អ្នកជំនាញចំនួន ៨នាក់ ទាក់ទិននឹងទីតាំងឧក្រិដ្ឋកម្មចំនួន០៨ បទបញ្ជាឲ្យរៀបអាពាហ៍ពិពាហ៍ និងការប្រព្រឹត្តលើពុទ្ធសាសនិកជន ជនជាតិចាម និងជនជាតិវៀតណាម។ នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសសាលក្រមដោយផ្ទាល់មាត់នៅក្នុងសំណុំរឿង ០០២/០២ រួមជាមួយសេចក្តីសង្ខេបនៃការរកឃើញ និងបានជូនដំណឹងអំពីសាលក្រមជាបីភាសាធ្វើការនៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩។ អង្គជំនុំជម្រះបានរកឃើញ ថា នួន ជា និង ខៀវ សំផន មានពិរុទ្ធភាពពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ និងបទប្រល័យពូជសាសន៍ប្រឆាងនឹងក្រុមជនជាតិពិន្ទុ ក្រុមជាតិសាសន៍ និងក្រុមពូជសាសន៍វៀតណាម ក្រោមទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ។ ទាំង នួន ជា ទាំង ខៀវ សំផន ត្រូវបានស្រេចឲ្យជាប់ពន្ធនាគារអស់មួយជីវិត។ អង្គជំនុំជម្រះបានពិចារណាទោសជាប់ពន្ធនាគារអស់មួយជីវិតដែលបានកំណត់លើ នួន ជា និង ខៀវ សំផន នៅក្នុងសំណុំរឿង ០០២/០១ ហើយបានស្រុបទោសនៅក្នុងសំណុំរឿង ០០២/០១ និង ០០២/០២ ជាទោសជាប់ពន្ធនាគារអស់មួយជីវិត។

២៨ នៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ អង្គជំនុំជម្រះសាលាដំបូងបានចុះសេចក្តីជូនដំណឹងបណ្តឹងសាទុក្ខរបស់ នួន ជា និង ខៀវ សំផន និងបានបញ្ជូនសំណុំរឿងទៅអង្គជំនុំជម្រះតុលាការកំពូល។

### ខ. *សំណុំរឿង០០៣ សំណុំរឿង០០៤/០២ និងសំណុំរឿង០០៤*

២៩ កិច្ចស៊ើបសួរក្នុងសំណុំរឿង០០៣ និង ០០៤ ត្រូវបានផ្តួចផ្តើមក្រោយពីដីកាបញ្ជូនរឿងឲ្យស៊ើបសួរត្រូវបានដាក់ដោយសហព្រះរាជអាជ្ញាអន្តរជាតិក្នុងឆ្នាំ២០១៩។ បន្ទាប់មក សំណុំរឿង០០៤ ត្រូវបានបំបែកជាបីសំណុំរឿងផ្សេងគ្នា ក្នុងនោះ សំណុំរឿងចំនួន ២ នៅដំណើរការនៅឡើយគឺ៖ សំណុំរឿង ០០៤/២ ពាក់ព័ន្ធនឹង អោ អាន និងសំណុំរឿង០០៤ ពាក់ព័ន្ធនឹង យឹម ទិត្យ។

៣០ នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ អង្គបុរេជំនុំជម្រះបានចេញសេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/០២។ អង្គជំនុំជម្រះសាលាដំបូងបានទទួលឯកសារសរុបចំនួន ៩ នៅក្នុងរឿងក្តីនេះ[15]។ នៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២០ អង្គជំនុំជម្រះបានចេញសេចក្តីថ្លែងការណ៍មួយដោយថ្លែងថា "អង្គជំនុំជម្រះមិនដែលបានទទួលការជូនដំណឹងជាផ្លូវការអំពីសំណុំរឿងនេះទេ ហើយអង្គជំនុំជម្រះមិនបានទទួលសំណុំរឿងនេះឡើយ" និងបន្ថែមថា "ការចេញសេចក្តីសម្រេចជាផ្លូវការមួយរបស់អង្គជំនុំជម្រះសាលាដំបូងមិនអាចធ្វើទៅបាន"[16]។ នៅថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២០ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់បណ្តឹងសាទុក្ខភ្លាមៗទៅអង្គជំនុំជម្រះតុលាការកំពូលក្រោមវិធាន ១០៤(៤)(ក) ដោយលើកទឡ្ហីករណ៍ថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់នៅក្នុងការធ្វើសេចក្តីថ្លែងការណ៍របស់ខ្លួន និង "បិទបញ្ចប់" សំណុំរឿង០០៤/០២។ នៅក្នុងសំណើរបស់ខ្លួនសហព្រះរាជអាជ្ញាអន្តរជាតិស្នើអង្គជំនុំជម្រះតុលាការកំពូល "សម្រេចថា [អង្គជំនុំជម្រះសាលាដំបូង] បានទទួលសំណុំរឿង ០០៤/០២ និង បង្គាប់ [អង្គជំនុំជម្រះ] បើកសវនាការលើរឿងក្តីនេះដោយឆាប់រហ័ស"។ យោងតាមវិធាន ១០៨.៤(ស្ទួន)(ខ) អង្គជំនុំជម្រះតុលាការកំពូលត្រូវសេម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តី សម្រេចក្នុងអំឡុងពេល៣ឬ៤ខែក្នុងករណីពិសេស[17]។

៣១ រង់ចាំរហូតដល់មានសេចក្តីសម្រេចចុងក្រោយថាតើសំណុំរឿងទាំងអស់ ឬណាមួយនៃសំណុំរឿង ០០៣ សំណុំរឿង ០០៤/០២ និងសំណុំរឿង០០៤ ត្រូវបញ្ជូនទៅជំនុំជម្រះ ទើបអាចមានការប៉ាន់ប្រមាណលើពេលវេលាដែលត្រូវការដើម្បីបញ្ចប់សវនាការទាំងនេះ។ ការវាយតម្លៃទៅលើពេលវេលា ដែលត្រូវការអាចនឹងពឹងផ្អែកលើចំនួនចុងចោទ និងភាពស្មុគស្មាញនៃអង្គហេតុ និងអង្គច្បាប់នៃបទចោទទាំងឡាយដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះផង។

---

[15] មេធាវីការពារក្តី និងសហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ឯកសារជូនទៅអង្គជំនុំជម្រះសាលាដំបូង។

[16] សេចក្តីថ្លែងការណ៍នេះមាននៅក្នុង https://www.eccc.gov.kh/en/articles/statement-judges-trial-chamber-eccc-regarding-case-0042-involving-ao។

[17] ក្នុងខែសីហា ឬខែកញ្ញា ឆ្នាំ២០២០។

## V. ផែនការបញ្ចប់បណ្តឹងសាទុក្ខ

### ក. *សំណុំរឿង០០២/០២*

៣២ នៅថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៩ នួន ជា បានទទួលមរណភាព ក្នុងអាយុ៩៣ឆ្នាំ ខណៈដែល កំពុងទទួលព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត រាជធានីភ្នំពេញ។ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ចប់កិច្ចនីតិវិធីបណ្តឹងសាទុក្ខលើ នួន ជា នៅថ្ងៃទី១៣ ខែសីហា ហើយនៅថ្ងៃទី២២ ខែវិច្ឆិកា បានចេញសេចក្តីបញ្ជាក់បំភ្លឺអំពីវិបាកគតិយុត្តកើតចេញពីមរណភាពរបស់ នួន ជា នៅក្នុងដំណាក់កាលនីតិវិធីនេះ[18]។

៣៣ នៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៩ សហព្រះរាជអាជ្ញាបានដាក់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមជំនុំជម្រះ ដោយមានមូលដ្ឋានតែមួយប៉ុណ្ណោះ។ ដោយពិចារណាលើទំហំ កម្រិត និងភាពស្មុគស្មាញនៃកិច្ចនីតិវិធីរបស់សំណុំរឿង០០២/០២ និងបញ្ហាផ្លូវច្បាប់ និង/ឬអង្គហេតុដែលបង្ហាញដោយមេធាវីការពារក្តី ខៀវ សំផន នៅក្នុងសេចក្តីជូនដំណឹងបណ្តឹងសាទុក្ខ[19] អង្គជំនុំជម្រះតុលាការកំពូលបានអនុញ្ញាតរយៈពេល១៨០ថ្ងៃបន្ថែមក្នុងការដាក់បណ្តឹងសាទុក្ខ តែមួយភាសា[20]។ អនុវត្តតាមការអនុញ្ញាតមេធាវីការពារក្តីបានដាក់សារណាបណ្តឹងសាទុក្ខចំនួន ៧៥០ ទំព័រ តែមួយភាសា នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០។ អង្គជំនុំជម្រះបានណែនាំថា ចម្លើយតបទៅនឹងសារណាបណ្តឹងសាទុក្ខត្រូវដាក់ក្នុងរយៈពេល

---

[18] អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់បំភ្លឺថា ការរំលត់កិច្ចដំណើរការនីតិវិធីពុំអាចធ្វើឱ្យការសម្រេចនៅក្នុងសាលក្រមពាក់ព័ន្ធនឹង នួន ជា ឥតបានការនោះទេ ហើយក៏ពុំមែនមានន័យថា ក្រោយពេលធ្វើកោសល្យវិច័យ ការសម្រេចនោះក្លាយជាគ្មានពិរុទ្ធភាពនោះឡើយ។ តុលាការមិនអាចចេញសាលក្រមស្តាពរលើពិរុទ្ធភាព ឬភាពគ្មានទោសរបស់ នួន ជា នោះទេ ដោយហេតុថា មរណភាពរបស់គាត់មិនអាចឱ្យតុលាការកំពូលសើរើរឿងក្តីរបស់គាត់ ហើយមរណភាពរបស់ នួន ជា ពុំប៉ះពាល់លើការបង្គាប់សំណងដល់ដើមបណ្តឹងរដ្ឋប្បវេណីដែលអង្គជំនុំជម្រះសាលាដំបូងបានទទួលយករួចហើយនោះទេ។

[19] មេធាវីការពារក្តីបានបង្ហាញកំហុសអង្គច្បាប់ និង/ឬអង្គហេតុចំនួនប្រមាណ ១៨២៤ ចំណុច នៅក្នុងសាលក្រមជំនុំជម្រះ និងសេចក្តីសម្រេចចំនួន ៣៥៥ ផ្សេងទៀត (១៥៩ ផ្ទាល់មាត់ និង ១៩ ៦លាយលក្ខណ៍អក្សរ) របស់អង្គជំនុំជម្រះសាលាដំបូង។

[20] វិធាន១០៧(៤)នៃវិធានផ្ទៃក្នុងចែងថា សារណាបណ្តឹងសាទុក្ខត្រូវដាក់ក្នុងរយៈពេល៦០ថ្ងៃគិតចាប់ពីកាលបរិច្ឆេទនៃការជូនដំណឹងអំពីការប្តឹងសាទុក្ខ។ អង្គជំនុំជម្រះតុលាការកំពូលបានផ្តល់បន្ថែមនូវការបន្ថែមចំនួនទំព័រតាមការណែនាំអនុវត្ត ពី ៦០ ទំព័រ ដល់ ៧៥០ ទំព័រ។

01740180

១២០ថ្ងៃក្រោយពីការជូនដំណឹង [21] និងបានជូនដំណឹងដល់ភាគីថា ការឆ្លើយតបទៅនឹងចម្លើយតបនឹងត្រូវបើកសវនាការផ្ទាល់មាត់ដែលកំពុងគ្រោងនឹងធ្វើឡើងនៅក្នុងត្រីមាសទី១ ឆ្នាំ២០២១។ នៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២០ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចផ្តល់សហាព្រះរាជអាជ្ញាចំនួន ១៤៥ ទំព័រ បន្ថែម (សរុប៨៩៥ទំព័រ) ដើម្បីឆ្លើយតបបណ្តឹងសាទុក្ខរបស់ ខៀវ សំផន។

៣៤ នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩ មេធាវីការពារក្តី ខៀវ សំផន បានដាក់បណ្តឹងមិនទុកចិត្តចៅក្រមនៃអង្គជំនុំជម្រះតុលាការកំពូលចំនួន ០៦ រូប ដោយផ្អែកលើមូលដ្ឋាននៃការសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន នៅក្នុងសំណុំរឿង ០០២/០១។ អនុលោមតាមវិធាន ៣៤(៦) គណៈកម្មាធិការរដ្ឋបាលតុលាការបានជ្រើសរើសចៅក្រមពេញសិទ្ធិនៃអង្គបុរេជំនុំជម្រះចំនួន ០៥ រូប និងចៅក្រមបម្រុងអន្តរជាតិនៃអង្គបុរេជំនុំជម្រះចំនួន ០១រូប យកមកជំនួសចៅក្រមអង្គជំនុំជម្រះតុលាការកំពូលដែលត្រូវបានប្តឹង ដើម្បីពិចារណាលើបណ្តឹងមិនទុកចិត្ត។ សេចក្តីសម្រេចមួយរំពឹងថានឹងចេញនៅក្នុងត្រីមាសទី៣ ឆ្នាំ២០២០[22]។

៣៥ អង្គជំនុំជម្រះតុលាការកំពូលរំពឹងថា សាលដីកានឹងត្រូវចេញទាំងបីភាសាផ្លូវការនៅត្រឹមត្រីមាសទី៤ ឆ្នាំ២០២២។ ការព្យាករណ៍នេះគឺអាស្រ័យលើភាពស្មុគស្មាញ និងតម្រូវការនៃដំណើរការបណ្តឹងសាទុក្ខ រួមទាំងលទ្ធផលនៃបណ្តឹងមិនទុកចិត្ត និងកត្តាពាក់ព័ន្ធនានា ដូចជា បុគ្គលិកគ្រប់គ្រាន់ សុខភាព និងសម្បទារបស់ជនជាប់ចោទ ព្រមទាំងសេវាបកប្រែឯកសារទាន់ពេលវេលា។

## ខ. *សំណុំរឿង០០៣ សំណុំរឿង០០៤/០២ និង សំណុំរឿង០០៤*

៣៦ ប្រសិនបើសំណុំរឿង០០៣ សំណុំរឿង០០៤/០២ និងសំណុំរឿង០០៤ បន្តទៅមុខរហូតដល់ដំណាក់កាលជំនុំជម្រះនោះ បណ្តឹងឧទ្ធរណ៍ភ្លាមៗ ឬបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងអាចកើតឡើង។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ដោយហេតុថាយើងមិនដឹងថាសំណុំរឿងណាមួយដំណើរការរហូតដល់ដំណាក់កាលជំនុំជម្រះ និងមិនដឹងពីបទចោទណាខ្លះនោះ វាហាក់ដូចជា

[21] សេចក្តីណែនាំស្តីអំពីការដាក់ឯកសារ មាត្រា ៧.១ តម្រូវឱ្យឯកសារទាំងអស់ត្រូវដាក់ជាភាសាខ្មែរ និងជាភាសាអង់គ្លេស ឬភាសាបារាំង។ បណ្តឹងសាទុក្ខត្រូវបានដាក់ជាភាសាបារាំង និង ឯកសារបកប្រែជាភាសាខ្មែរត្រូវបានជូនដំណឹងនៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២០។

[22] សេចក្តីសម្រេចត្រូវបានចេញនៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២០ ជាឯកច្ឆន្ទ ដោយបដិសេធបណ្តឹង។

ឆាប់ពេកក្នុងការផ្តល់នូវការប៉ាន់ស្មានចំពោះពេលវេលាដែលតម្រូវក្នុងការសម្រេចលើបណ្តឹងសាទុក្ខណាមួយនៃសំណុំរឿងពាក់ព័ន្ធ។

## VI. សេចក្តីសន្និដ្ឋាន

៣៧ សម្រាប់*ឆ្នាំ២០២០* យើងរំពឹងថានឹងសម្រេចបានព្រឹត្តិការណ៍សំខាន់មួយ គឺ (i) ការចេញសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៣ ប្រឆាំង មាស មុត ថាតើត្រូវបញ្ជូនរឿងក្តីទៅជំនុំជម្រះ ឬបញ្ចប់កិច្ចដំណើរការនីតិវិធី។

៣៨ សម្រាប់*ឆ្នាំ២០២១* ព្រឹត្តិការណ៍សំខាន់មួយត្រូវបានរំពឹងទុកគឺ (ii) ការចេញសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍លើដីកាដំណោះស្រាយក្នុងសំណុំរឿង០០៤ ថាតើត្រូវបញ្ជូន ទៅជំនុំជម្រះ ឬបញ្ចប់កិច្ចដំណើរការនីតិវិធី។ និង

៣៩ សម្រាប់*ឆ្នាំ២០២២* ព្រឹត្តិការណ៍សំខាន់មួយត្រូវបានរំពឹងទុកគឺ (iii) ការចេញសាលដីកាក្នុងសំណុំរឿង ០០២/០២ ដោយអង្គជំនុំជម្រះតុលាការកំពូល។

៤០ ក្នុងករណីដែលសំណុំរឿង០០៣ សំណុំរឿង០០៤ និងសំណុំរឿង ០០៤/០២ ត្រូវបញ្ជូនទៅជំនុំជម្រះទាំងមូល ឬដោយផ្នែក ពេលវេលាកំណត់សម្រាប់សំណុំរឿងទាំងនេះនឹងត្រូវព្យាករណ៍នៅពេលនោះ។

៤១ ព្រឹត្តិការណ៍សំខាន់ៗដែលបានព្យាករមានបង្ហាញជូនក្នុងតារាងដែលភ្ជាប់ជាមួយនឹងផែនការនេះ។

01740182

# តារាងកំណត់ពេលវេលាតាមការគ្រោងទុកដែលរួមមានព្រឹត្តិការណ៍សំខាន់ៗ

គម្រោងបញ្ចប់ផែនការ កំណែលើកទី ២៥ - ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០




(ច) ដីកាដំណោះស្រាយដាច់ដោយឡែកតែមួយភាសា

(ឆ) ដីកាដំណោះស្រាយដាច់ដោយឡែកជាភាសាអង់គ្លេស និងភាសាខ្មែរ

(ជ) សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះទៅលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ